គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

Coalition for Partnership in Democratic Development
អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

# សិក្ខាសាលាជាតិ
# ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០
# នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩**

បទបង្ហាញរបស់លោកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិស្តីទី
នៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងជាតំណាងអង្គការសង្គមស៊ីវិល
អំពីការចូលរួមបដិភាគរបស់អង្គការសង្គមស៊ីវិលក្នុងសកម្មភាពកំណែទម្រង់ស្ទូល

---

**ជាបឋម នាងខ្ញុំសូមគោរព! សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា បង ប្អូន ជាភ្ញៀវជាតិ និងអន្តរជាតិ និង អង្គវេទិកាទាំងមូល!**

ក្នុងនាមអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ជាង២០០ ជាសមាជិក និងអង្គការជាដៃគូនានាដូចជា អង្គការសម្ពន្ធ័ភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ (CPDD) នាងខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានរៀបចំ និងអនុញ្ញាតឲ្យនាងខ្ញុំ និងសហសេវិកពីសង្គមស៊ីវិលបានចូលរួមក្នុង**សិក្ខាសាលាជាតិ ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។**

អង្គការសង្គមស៊ីវិលសូមស្វាគមន៍នូវការខិតខំប្រឹងប្រែងរបស់ **លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ក្នុងកំណែទំរង់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានការរីកចម្រើនគួរឲ្យកត់សំគាល់ជាច្រើន៕ ជាពិសេស ការខិតខំឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និរន្តរភាព និងការបង្កើនថវិកាដល់ក្រុង/ស្រុក និងសង្កាត់/ឃុំ ។

នាងខ្ញុំសូមសម្តែងនូវការគាំទ្រ**ផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ដែលមានចង្កោមសកម្មភាព សកម្មភាព និងអនុសកម្មភាព ដែលមានលក្ខណៈនវានុវត្ត បរិយាបន្ន ព្រមទាំងផែនការថវិកាដែលមានលក្ខណៈវិសហមជ្ឈការកាន់តែច្រើនក្នុងឆ្នាំ២០១៩ និងឆ្នាំកន្លងទៅ។

ដើម្បីឲ្យផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ កាន់តែមាន ប្រសិទ្ធផល និង ប្រសិទ្ធភាព ព្រមទាំងសង្គតិភាពទៅនឹងការប្រែប្រួលបរិបទ យើងខ្ញុំសូមចូលរួមចែករំលែកអនុសាសន៍មួយចំនួន ដែលបានប្រមូលពីសមាជិកអង្គការសង្គមស៊ីវិល ដូចខាងក្រោមនេះ ៖

**<u>សំណើសំខាន់ៗជាទូទៅ</u>៖**

- សូមបន្តជានាឲ្យកាន់តែមាន**បរិយាកាសអំណោយផល ជាពិសេស ការអនុវត្តក្របខ័ណ្ឌច្បាប់ប្រកបដោយគតិយុទ្ធ ដើម្បីលំហប្រជាធិបតេយ្យ កិច្ចសហប្រតិបត្តិការ និងការចូលរួមពេញលេញក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗដូចជា** អង្គការសង្គមស៊ីវិល សកម្មជន និង ប្រជាពលរដ្ឋ ជាដើម។
- សូមពន្លឿននូវការធ្វើវិសោធនកម្មច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ពាក់ព័ន្ធនានា ដោយទទួលយកធាតុចូលរបស់អង្គការសង្គមស៊ីវិលពីគ្រប់វិស័យ។
- សូម បង្កើតយន្តការ គោលយោបាយ និងការវិភាជថវិកាសម្រាប់គំនិតផ្តួចផ្តើម **ភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។**
- សូមបង្កើនសកម្មភាពផ្សព្វផ្សាយ និងផ្តល់ការយល់ដឹង ដល់ប្រជាពលរដ្ឋ សង្គមស៊ីវិល អជ្ញាធរមូលដ្ឋាន និងវិស័យឯកជន អំពី **គោលដៅអភិវឌ្ឍន៍ប្រកបចីរភាពសម្រាប់កម្ពុជា** ដែលបានធ្វើ

មូលដ្ឋានីយកម្មជោគជ័យ រួមទាំងជម្រុញ និង លើកទឹកចិត្តឲ្យពួកគេបានចូលរួមអនុវត្តសកម្មភាពនានាៗ និងត្រួតពិនិត្យ វាយតម្លៃ ចំពោះភាពរីកចម្រើនតាមគោលដៅនិងវិស័យនីមួយៗ។

- ស្វែងរកដំណោះស្រាយ និងការឆ្លើយតបឲ្យបានរហ័ស និងមានប្រសិទ្ធភាពទៅនឹងក្តីបារម្ភរបស់ប្រជាពលរដ្ឋ ចំពោះការបាត់បង់ឱកាសបទទួលបានបន្តនូវ ការអនុគ្រោះពន្ធតាមរយៈ EBA របស់សហគមន៍ អឺរ៉ុប និង GSP របស់សហរដ្ឋអាមេរិក ដែលការបាត់បង់ប្រពន្ធ័ទាំងពីរនេះ នឹងអាចផ្តល់ផលប៉ះពាល់អវិជ្ជមានជាខ្លាំងដល់ជីវភាពប្រជាជន សេដ្ឋកិច្ច និងសង្គមជាតិ។

## <u>សំណើសំខាន់ៗជាក់លាក់តាមចង្កោមសកម្មភាព</u>

### <u>១. ចង្កោមសកម្មភាព៖ ការគ្រប់គ្រងការងារកំណែទម្រង់</u>

1. ក្រុមប្រឹក្សារាជធានីខេត្ត ក្រុងស្រុក សង្កាត់ឃុំ បង្កើនភាពសកម្មក្នុងការលើកកំពស់ភាពជាតំណាងសម្រាប់មតិភាគច្រើន និងមតិភាគតិច ការចូលរួមរបស់ប្រជាពលរដ្ឋ សកម្មជន និងអ្នកពាក់ព័ន្ធនានាដោយមិនប្រកាន់និន្នាការនយោបាយណាមួយ ក្នុងការពិភាក្សាពីគោលនយោបាយ ផែនការ និងការតាមដានលើកម្មវិធីអភិវឌ្ឍន៍នានា។

### <u>២. ចង្កោមសកម្មភាព៖ អភិបាលកិច្ចល្អ</u>

1. ការពង្រឹង គណនេយ្យភាពសង្គមក្នុងក្រុងស្រុកគោលដៅ ចំនួន១៨៣ និងផ្តោតលើសេវានានាស្របជាមួយនឹងការផ្ទេរមុខងារដូចនៅក្នុងចង្កោមសកម្មភាព៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។
2. ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធនានាគួររៀបចំឲ្យមានការផ្សព្វផ្សាយ លើកកម្ពស់ការយល់ ដឹងច្បាប់ក៏ដូចជានីតិវិធីអនុវត្តន៍ ព្រមទាំងមានជនបង្គោល ឬមន្ត្រីទំនាក់ទំនងច្បាស់លាស់ សម្រាប់ពេលមានបញ្ហាពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធនឹងអង្គការ

សង្គមស៊ីវិល។ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម គួរត្រូវបានពន្យាពេលអនុវត្តចំពោះអង្គការសង្គមស៊ីវិល ហើយរាជរដ្ឋាភិបាលគួរគាំទ្រ និងសម្របសម្រួលអង្គការសង្គមស៊ីវិលអោយមានសមត្ថភាព និងធនធានគសមស្របសម្រាប់រៀបចំប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុផ្ទៃក្នុង និងអ្នកពាក់ព័ន្ធ រួមទាំងម្ចាស់មូលនិធិ។

3. ពង្រឹងការអនុវត្តកម្មវិធីស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈនៅរដ្ឋបាលថ្នាក់ ក្រោមជាតិ ការចូលរួមរបស់យុវជន និងតួនាទីរបស់ពួកគេក្នុងសកម្មភាពអភិវឌ្ឍ និងតំណែងវិជ្ជាជីវៈនៅរដ្ឋបាលថ្នាក់ ក្រោមជាតិគួរត្រូវបានចាត់ទុកជាអាទិភាព។

## ៣. ចង្កោមសកម្មភាព៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

1. សូមធានានូវភាពឯករាជ្យរបស់មន្ត្រីរាជការថ្នាក់ក្រោមជាតិ ដោយធានានូវភាពមិនជាប់ពាក់ព័ន្ធ នឹងគណបក្សនយោបាយ ការវាយតម្លៃ ការបំពេញការងារ ប្រព័ន្ធវាយតម្លៃគុណផលដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងការតំឡើងកាំប្រាក់ខែ និងតួនាទីដោយផ្អែកលើស្នាដៃការងារ។
2. ការពង្រឹងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការបំពេញការងារ និងការទទួលខុសត្រូវរបស់ខ្លួន ដោយផ្អែកលើតម្រូវការពិតប្រកដរបស់មន្ត្រី សម្រាប់ឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ ។ ប្រធានបទសំខាន់មួយចំនួនសំរាប់ឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋគឺអភិក្រមការអភិវឌ្ឍដោយផ្អែកលើសិទ្ធិជាមូលដ្ឋាន និងភាពជាដៃគូប្រកបដោយបរិយាបន្ន។

## ៤. ចង្កោមសកម្មភាព៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន

1. ភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវា និង ការអភិវឌ្ឍមូលដ្ឋាន ចូលរួមក្នុងដំណើរការផ្តេរមុខងារក្នុងវិស័យផ្សេងៗ។

## ៥. ចង្កោមសកម្មភាព៖ វិសហមជ្ឈការហិរញ្ញវត្ថុៈ

1. បង្កើនថវិកាសម្រាប់ក្រុង ស្រុក សង្កាត់ និង ឃុំ ឲ្យបានច្រើនជាងថវិកាវាជធានី ខេត្ត ស្របតាមភាពស្នូលនៃកំណែទំរង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ លើសពីនេះ ធានាថាថវិកាថ្នាក់ក្រោមជាតិដែលកើនត្រូវធានាគាំទ្រគម្រោងអភិវឌ្ឍន៍សង្គម សម្រាប់អ្នកក្រីក្រ ក្រុមងាយរងគ្រោះ យ៉ាងតិច២០ភាគរយ នៃថវិកាឃុំ និង ១០ភាគរយថវិកាស្រុកតាមប្រកាសក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចអោយកើតឡើងពិតប្រាកដ ទោះក្រុមប្រឹក្សាឃុំស្រុកមានអភ័យឯកសិទ្ធស្វ័យសម្រេច ។ការអនុវត្តកម្មវិធីអភិវឌ្ឍគួរតាមរូបមន្ត ៥០ បូក ៥០ ឬ ១០០%ដោយសង្គមស៊ីវិល។

2. ថវិកាចំណូលពីច្រកចេញចូលតែមួយ គួរប្រើប្រាស់សម្រាប់ការលើកម្ពស់ផ្សព្វផ្សាយសេវាច្រកចេញចូលតែមួយនិងសេវាសាធារណៈផ្សេងៗ និងសកម្មភាពបំពេញតួនាទីថ្មីរបស់ការិយាល័យប្រជាពលរដ្ឋថ្នាក់ខេត្ត និងក្រុងស្រុកព្រោះប្រជាជនអត់យល់ដឹងទេ ពីសេវាល្អរហ័យទាន់ចិត្ត និងមិនពុករលួយ។

**សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរព!**

ជាថ្មីម្តងទៀត យើងខ្ញុំសូមបញ្ជាក់ថា សង្គមស៊ីវិលប្តេជ្ញាចិត្ត ដើរតួនាទីយ៉ាងសំខាន់ក្នុង **ការអភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាពសម្រាប់ ប្រទេសកម្ពុជា។**

មុននឹងបញ្ចប់ យើងខ្ញុំសូមសម្តែងការកោតសរសើរ និងថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំនិងសហការីទាំងអស់របស់ **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម** ជាពិសេស **សម្តេច ក្រឡាហោម ស ខេង ជាប្រធាន គជអប** ដែលជានិច្ចកាល តែងតែជួយគាំ

ទ្រដល់ អង្គការសង្គមស៊ីវិល ឲ្យបន្តនូវបេសកម្មរបស់ខ្លួន ក្នុងភាពជាដៃគូប្រកបដោយបរិយាបន្នក្នុងការអភិវឌ្ឍ។

យើងខ្ញុំមានក្តីរំពឹងទុកយ៉ាងមុតមាំថា យើងទាំងអស់គ្នា (ទាំងរដ្ឋាភិបាល ទាំងសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍ) នឹងកាន់តែមានជំនឿទុកចិត្តចំពោះគ្នា មានសេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ និងសាមគ្គីភាពយ៉ាងស្អិតរមួតដើម្បីសម្រេចនូវបំណងប្រាថ្នារួមនេះ**កម្ពុជាមានការអភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាពជានិរន្ត** សម្រាប់ជា**មរតកដ៏ថ្លៃថ្លា**ដល់**អ្នកជំនាន់ក្រោយៗ**របស់ពួកយើង។

សូមអរគុណ!